# ស្ថានីយផូស៊ីលភ្នំបាណន់

ភ្នំបាណន់ មានទីតាំងស្ថិតនៅ ភូមិបាណន់ ឃុំកន្ទឺពីរ ស្រុកបាណន់ ខេត្តបាត់ដំបង ដោយមានចំងាយប្រមាន២២គីឡូម៉ែត្រ។ ភ្នំបាណន់ ក៏ជាទីតាំងប្រវត្តិសាស្ត្រមួយដ៏ល្អឯកដ្បិតមានប្រាសាទភ្នំបាណន់ដែលជាសំណង់ប្រាសាទបុរាណមួយ ដែលសល់តាំងពីមុនអង្គរ។ ប្រាសាទភ្នំបាណន់មានរាងចតុកោណកែង សង់ឡើងនៅដើមស.វទី១១ មានតួប៉មចំនួន៥ ដោយតួប៉មកណ្ដាលធ្វើពីថ្មភក់ និងតួប៉ម៤ជុំវិញ ធ្វើពីថ្មភក់ លាយថ្មបាយក្រៀម ហើយស្ថិតក្នុងរចនាបថមុនអង្គរ។ ក្រៅពីនេះ ភ្នំបាណន់ក៏មានរឿងព្រេងទាក់ទងនឹងនាងរំសាយសក់ ដោយបានបង្ហាញពីទីតាំងនេះជាសមុទ្រ។[១] ចំពោះរឿងព្រេងនេះក៏មានទំនាក់ទំនងនិងរឿងភ្នំសំពៅផងដែរ ហើយចំណុចមួយទៀតបានបញ្ជាក់ថាទីតាំងនោះគឺស្ថិតនៅក្បែរសមុទ្រ ។ វាហាក់ដូចជាមានទំនាក់ទំនងជាមួយអតីតកាលនៃធម្មជាតិរបស់ភ្នំនេះផងដែរ ។ ក្នុងអត្ថបទនេះនឹងបង្ហាញថា តើទីតាំងនេះជាសមុទ្របានយ៉ាងដូចម្ដេច? និងវត្ថុអ្វីខ្លះជាភស្តុតាងដែលបង្ហាញថាទីតាំងនេះជាសមុទ្រ?

ភ្នំបាណន់ជាប្រភេទភ្នំថ្មកំបោរ (រូបលេខ២) ដែលមានកំណត់សំគាល់ PLS ដែលមានអាយុកាល ក្នុងសម័យ Permian Period (251-299 លានឆ្នាំ)។[២] ថ្មកំបោរទាំងឡាយកើតឡើងដោយការកកនៃកំណកកំបោរដែលបានមកពីសត្វសមុទ្រ ខ្យង ខ្ចៅជាដើម ដោយប្រើប្រាស់ពេលរាប់ម៉ឺន សែនឆ្នាំ។ យើងបានរកឃើញភស្តុតាងមួយចំនួនដែលជាផូស៊ីលសត្វសមុទ្រដូចជា៖

១. ពពួកគ្រីណូអ៊ីត Crinoid (រូបទលេខ៣) ដែលក្រុមនេះស្ថិតនៅក្បែរពពួកផ្កាយសមុទ្រ និងពួកកាំប្រម៉ាសមុទ្រ យើងក៏ធ្លាប់បានចុះផ្សាយលើកមុនផងដែរក្នុងគេហទំព័រ AMS អរិយធម៌ខ្មែរ។[៣] ពពួកសត្វគ្រីណូអ៊ីត ដែលយើងបានឃើញនៅភ្នំបាណន់នេះ ត្រូវបានកប់ចូលក្នុងសាច់ថ្ម។ មានន័យថាពពួកនេះវាបានកើតមុនថ្មកំបោរតាំងពីពេលថ្ម

---

[១] ប្រជុំរឿងព្រេងខ្មែរភាគ៥ ទំព័រ១៤៣-១៤៧

[២] General Department of Mineral Resource, 2010, Geological Map of Cambodia

[៣] https://ams.com.kh/khmercivilization/detail/7547

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

កំបោរនៅជាដីនៅឡើយ។ សត្វគ្រីណូអ៊ីតនេះបានបន្តរស់មកដល់ពេលបច្ចុប្បន្ន គ្រាន់តែពូជន៍ផ្សេងគ្នាតែប៉ុណ្ណោះក្នុងប្រទេសកម្ពុជាក៏នៅមានផងដែរ (រូបលេខ២) ។

២. ងាវ ? វាពិតជាមានរូបរៀងដូចងាវណាស់ ដែលជាប់នឹងផ្នែកខាងក្រៅនៃថ្មកំបោរ(រូបលេខ៥)។ ពពួកងាវនេះស្ថិតនៅក្នុងក្រុម Bivalve ដែលមានដុចជា លៀស គ្រំផងដែរ ។ ក្រុមនេះមានកំណើត តាំងពីស័កទី១ Paleozoic (៥៤២-២៥២លានឆ្នាំ) មកម្ល េះតែមិនសូវសម្បូរទេ បន្តមកស័កទី២ Mesozoic (២៥២-៦៥លាន)[៨] និងបន្តរហូតដល់ពេលបច្ចុប្បន្ន។ សម្រាប់រូបភាពមួយនេះតើវាត្រូវបានកកតាមក្រោយ នៅពេលដែលវានៅមានសមុទ្រនៅឡើយឬយ៉ាងណា? លុះត្រាមានការសិក្សាបន្ថែមដោយយើងនៅមានទិន្នន័យតិចនៅឡើយ។

៣. អាគីង Barnacles ជាប្រភេទសត្វ ដែលអាចផ្លាស់ទីបានយឺត(រូបលេខ៦-៧)។ ខ្លួនពួកវាស្រោបដោយសំបក មានរាងស្រួចនៅផ្នែកខាងចុង ពួកនេះច្រើនតែទុំនៅលើឈើ ដែលអណ្ដែត សត្វសមុទ្រមួយចំនួនដែលមានសំបករឹង និងខ្លះវាទុំនៅលើថ្ម។[៩] ពពួកនេះបានរស់មកដល់បច្ចុប្បន្ន ដែលយើងអាចឃើញតាមថ្មនៅតាមមាត់សមុទ្រ។ តាមរយៈការរស់នៅនៃពពួកអាគីងនេះអាចបញ្ជាក់ថា ពួកនេះអាចរស់នៅក្រោយពេលដែលតំបន់នេះទៅជាកោះ និងអាចខ្លាយជាថ្មហើយ?

តាមរយៈការចុះសិក្សាស្រាវជ្រាវជាបឋមរបស់ក្រុមការងារនៅតំបន់ភ្នំបាណន់នេះ គឺយើងបានជួបប្រទះនៅផូស៊ីលសត្វសមុទ្រតិចតួចទេ។ តែទោះជាយ៉ាងណាក៏យើងអាចយល់ដឹងជាបឋមថា ទីតាំងភ្នំបាណន់នេះ គឺមានប្រវត្តិសាស្ត្រធម្មជាតិ ដែលធ្លាប់មានអតីតកាលនៅក្នុងសមុទ្រ។ តែយើងពុំដឹងថាសមុទ្របានដកថយចេញពីតំបន់នោះតាំងពីពេលណានោះទេ? ដ្បិតយើងត្រូវការស្វែងយល់នៅកស្តុតាង និងការសិក្សាស្រាវជ្រាវបន្ថែមទៀតដើម្បីឱ្យយល់កាន់តែច្បាស់។ ម្យ៉ាងទៀតទីតាំងនេះ បច្ចុប្បន្នមានសំណង់ប្រាសាទបុរាណនៅលើកំពូលភ្នំ និងជាតំបន់ប្រជុំជន ដ៏សំខាន់មួយកាលពីសម័យបុរាណរហូតមកបច្ចុប្បន្ន និងជាតំបន់ទេសចរណ៍គួឱ្យទាក់ទាញមួយផងដែរ។

---

[៨] https://www.digitalatlasofancientlife.org/learn/brachiopoda/brachiopoda-vs-bivalvia/

[៩] ២០០៨, សៀវភៅមគ្គុទេសក៏អំពី ធនធានជលផលសមុទ្រ នៅព្រះរាជាណាចក្រកម្ពុជា, ទំព័រ ៩៣

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១ ប្រាសាទភ្នំបាណន់ សាងស.វទី១២គ.ស



រូបលេខ២ ថ្មគំបោរ រូងភ្នំ នៅភ្នំបាណន់

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបទី៣ ពពួកសត្វគ្រីណូអ៊ីត ដែលកប់ក្នុងថ្មកំបោរ



រូបទី៤ ប្រភេទមួយនៃសត្វគ្រីណូអ៊ីត នៅសមុទ្រនៃប្រទេសកម្ពុជា ប្រភពរូប Amick

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបទី៦ ងាវ នៅភ្នំបាណន់



រូបទី៧ អាគឹង នៅភ្នំបាណន់

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបទី៨ អាគីធ៍ នៅភ្នំបាណន់

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ